# ធ្វើផ្លូវបេតុងក្រាលកៅស៊ូមួយខ្សែជូនអ្នកភូមិមណ្ឌល១






*លោកឃឹម ប៊ុនសុង ចូលរួមពិធីបើកការដ្ឋានធ្វើផ្លូវក្រាលបេតុង និងចាក់កៅស៊ូប្រភេទបេទីមីណឺ នៅភូមិមណ្ឌល១ (រូបថត:គួលែន)*

**សៀមរាប** ៖ កាលពីព្រឹកថ្ងៃទី៥ខែមករាឆ្នាំ២០១៤ អាជ្ញាធរខេត្តសៀមរាបបានបើកការដ្ឋានធ្វើផ្លូវបេតុង ហើយក្រាលកៅស៊ូបេទីមីណឺពីលើមួយខ្សែប្រវែង១៥០ម៉ែត្រ ដើម្បីធ្វើឱ្យផ្លូវក្នុងក្រុងសៀមរាប កាន់តែប្រសើរឡើងសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិ ក៏ដូចជាសម្រាប់ប្រជាពលរដ្ឋធ្វើដំណើរទៅមកបានស្រួល។

លោកទេព ប៊ុនឆាយ អភិបាលក្រុងសៀមរាប បានមានប្រសាសន៍ថា កំណាត់ផ្លូវនេះ គឺធ្វើឡើងក្នុងគោលបំណងឱ្យប្រជាពលរដ្ឋមានផ្លូវល្អ, មានសុវត្ថិភាព, និងអាចបង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរទៅមក ដើម្បីប្រកបអាជីវកម្មប្រចាំថ្ងៃ និងឈានទៅរកការរីកចម្រើននៅក្នុងក្រុងសៀមរាប សក្តិសមជាទីក្រុងទេសចរណ៍។

លោកឃឹម ប៊ុនសុង អភិបាលខេត្តសៀមរាប បានមានប្រសាសន៍ដែរថា កំណាត់ផ្លូវនេះ មានសារសំខាន់ណាស់។ ពិតមែនតែកំណាត់ផ្លូវនេះមានរយៈចម្ងាយខ្លី ប៉ុន្តែបានចំណាយទឹកប្រាក់ច្រើន។ ហើយនេះមិនមែនជាកំណាត់ផ្លូវទី១ ដែល អនុវត្តនៅក្នុងទីក្រុងសៀមរាបនោះទេ ព្រោះថាកន្លងមកផ្លូវក្នុងក្រុងបានអភិវឌ្ឍជាបណ្តើរៗរហូតមកដល់បច្ចុប្បន្ន មានផ្លូវជាច្រើនបានសម្ពោធដាក់ឱ្យប្រើប្រាស់រួចហើយ និងបន្តស្ថាបនា ឬជួសជុលថ្មី រួមទាំងការធ្វើប្រព័ន្ធលូ ប៉ែកខាងលិច និងប៉ែកខាងកើតក្រុងផងដែរ ។

លោកឃឹម ប៊ុនសុង បានឱ្យដឹងទៀតថា គម្រោងធ្វើផ្លូវក្រាលបេតុង និងចាក់កៅស៊ូប្រភេទបេទីមីណឺខាងលើនេះ គឺប្រើប្រាស់គម្រោងថវិការបស់សាលាខេត្តសៀមរាប ។ **គួលែន**